# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១១ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់វិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី........ ខែ......... ឆ្នាំ ............. នាសម័យប្រជុំពេញអង្គលើកទី...... នីតិកាលទី....... និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី........ ខែ.......ឆ្នាំ............ នាសម័យប្រជុំពេញអង្គ លើកទី........នីតិកាលទី....... ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

# ច្បាប់
# ស្តីពី
# គណនេយ្យ និង សវនកម្ម

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .- គោលបំណង**

ច្បាប់នេះ មានគោលបំណងគ្រប់គ្រងគណនេយ្យនិងសវនកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

**មាត្រា២ .- គោលដៅ**

ច្បាប់នេះមានគោលដៅ ៖

១. ពង្រីកនិងពង្រឹងសិទ្ធិអំណាចរបស់ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម។

២. ពង្រឹងសមត្ថភាពជំនាញនិងការទទួលខុសត្រូវរបស់គណនេយ្យករកម្ពុជា។

៣. ដាក់ឲ្យអនុវត្តស្តង់ដារគណនេយ្យកម្ពុជា ស្តង់ដារសវនកម្មកម្ពុជា និងស្តង់ដារពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជា។

៤. ដាក់ចេញនូវយន្តការ វិធាន និងនីតិវិធីសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តច្បាប់នេះ។

៥. លើកកម្ពស់វិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។

**មាត្រា៣ .- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះគ្រប់ស្ថាប័នសាធារណៈ សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងគណនេយ្យករកម្ពុជា។ How about auditor

**មាត្រា៤ .- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសទាំងឡាយដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ ។

# ជំពូកទី២
# ក្រុមប្រឹក្សាជាតិគណនេយ្យ

## មាត្រា៥ .- ការបង្កើតក្រុមប្រឹក្សាជាតិគណនេយ្យ

ក្រុមប្រឹក្សាជាតិគណនេយ្យ(សរសេរកាត់ថា **ក.ជ.គ.**) ត្រូវបានបង្កើតឡើងដោយច្បាប់នេះ និងត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ក.ជ.គ.** ត្រូវមានក្រុមប្រឹក្សាភិបាល ដែលត្រូវដឹកនាំដោយប្រធាន១(មួយ)រូប អមដោយអនុប្រធាន១(មួយ)ឬច្រើនរូប និងមានសមាជិកមួយចំនួនតាមការចាំបាច់។ ប្រធានក្រុមប្រឹក្សាភិបាល **ក.ជ.គ.** ត្រូវតែជាថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានឋានៈចាប់ពីរដ្ឋលេខាធិការឡើងទៅ។

**ក.ជ.គ.** ត្រូវមានអគ្គលេខាធិការដ្ឋាន១(មួយ) ជាសេនាធិការ ដែលត្រូវដឹកនាំដោយអគ្គលេខាធិការ១ (មួយ)រូប អមដោយអគ្គលេខាធិការរង១(មួយ)ឬច្រើនរូប តាមការចាំបាច់។

**ក.ជ.គ.** ត្រូវមានថវិកាផ្ទាល់ខ្លួននៅក្នុងកញ្ចប់ថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃ **ក.ជ.គ.** ត្រូវកំណត់ដោយអនុក្រឹត្យ ។ **(សួរក្រុមប្រឹក្សាអ្នកច្បាប់)**

## មាត្រា៦ .- មុខងារ និងភារកិច្ចរបស់ ក.ជ.គ.

**ក.ជ.គ.** មានមុខងារនិងភារកិច្ចដូចតទៅ ÷

១. ពិនិត្យនិងផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត។ what license?

២. ផ្ដល់ ព្យួរ និងដកហូតអាជ្ញាបណ្ណតាមលក្ខខណ្ឌដែលត្រូវកំណត់ដោយ **ក.ជ.គ.**។

៣. ដាក់ឲ្យអនុវត្តនិងធ្វើបច្ចុប្បន្នកម្មនូវ ÷

   ក- ស្តង់ដារគណនេយ្យកម្ពុជា

   ខ- ស្តង់ដារសវនកម្មកម្ពុជា

   គ- រាល់វិធានការនិងបទបញ្ញាបច្ចេកទេស ដើម្បីណែនាំការអនុវត្តចំពោះស្តង់ដារទាំងនោះ។

៤. តាមដាន និងត្រួតពិនិត្យលើឯកសារនិង/ឬដល់ទីកន្លែង ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តច្បាប់និងបទបញ្ញត្តិជាធរមាន។

៥. ដោះស្រាយបណ្ដឹងឬវិវាទដែលបានទទួល ដាក់ទណ្ឌកម្មខាងរដ្ឋបាលនិង/ឬទណ្ឌកម្មខាងវិន័យ ឬប្ដឹងទៅតុលាការ អំពីការបំពានលើបទប្បញ្ញត្តិនៃច្បាប់នេះ។

៦. តំណាងឲ្យព្រះរាជាណាចក្រកម្ពុជា ក្នុងរាល់កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានាជាដៃគូ ។

៧. រួមចំណែកលើកកម្ពស់វិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។

៨. អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រគល់ជូន ។

# ជំពូកទី៣
# វិទ្យាស្ថានគណនេយ្យករជំនាញកម្ពុជា

**មាត្រា៧ .- ការបង្កើតវិទ្យាស្ថានគណនេយ្យករជំនាញកម្ពុជា**

វិទ្យាស្ថានគណនេយ្យករជំនាញកម្ពុជា (សរសេរកាត់ថា **វ.គ.ជ.ក.**) ជាអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវបានបង្កើតឡើងដោយច្បាប់នេះ និងត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**វ.គ.ជ.ក.** ត្រូវមានក្រុមប្រឹក្សាភិបាល ដែលត្រូវដឹកនាំដោយប្រធាន១(មួយ)រូប អមដោយអនុប្រធាន១(មួយ)ឬច្រើនរូប និងមានសមាជិកមួយចំនួនតាមការចាំបាច់។

**វ.គ.ជ.ក.** ត្រូវមានស្នងការរាជរដ្ឋាភិបាល១(មួយ)រូប ជាទីប្រឹក្សាអមក្រុមប្រឹក្សាភិបាល។

**វ.គ.ជ.ក.** ត្រូវមានលេខាធិការដ្ឋាន១(មួយ) ជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃ **វ.គ.ជ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៨ .- មុខងារ និងភារកិច្ចរបស់ វ.គ.ជ.ក.**

**វ.គ.ជ.ក.** មានមុខងារនិងភារកិច្ចដូចតទៅ ÷

១. គ្រប់គ្រងសមាជិករបស់ខ្លួនដែលជាគណនេយ្យករកម្ពុជា។

២. កំណត់គុណវុឌ្ឍិនិងលក្ខខ័ណ្ឌនានាដើម្បីក្លាយជាគណនេយ្យករកម្ពុជា។

៣. លើកតម្កើងនិងការពារតម្លៃវិជ្ជាជីវៈ ផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈ។

៤. ដាក់ឱ្យអនុវត្ត និងធ្វើបច្ចុប្បន្នកម្មនូវក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជា។

៥. បង្កើតវិធាន និងបទបញ្ជាផ្ទៃក្នុង សម្រាប់សមាជិក **វ.គ.ជ.ក.**។

៦. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះការអនុវត្តក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជា និងដោះស្រាយរាល់ពាក្យបណ្តឹងពាក់ព័ន្ធ។

៧. លុបឬព្យួរសមាជិកភាពនៃសមាជិកដែលបានប្រព្រឹត្តខុសនឹងក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជា។

៨. បង្កើតនិងរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈគណនេយ្យ ដោយសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ និងបំប៉នសមត្ថភាពជំនាញដល់សមាជិក **វ.គ.ជ.ក.**។

៩. ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយ **ក.ជ.គ.** ដើម្បីលើកកំពស់វិស័យគណនេយ្យនិងសវនកម្ម និងត្រូវចាត់តំណាងរបស់ខ្លួនដើម្បីចូលរួមជាសមាជិកនៃ **ក.ជ.គ.**។

១០. អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រគល់ជូន ។

# ជំពូកទី៤

## ស្តង់ដារគណនេយ្យកម្ពុជា

### មាត្រា៩ .- ស្តង់ដារគណនេយ្យកម្ពុជា

ស្តង់ដារគណនេយ្យកម្ពុជា គឺជាស្តង់ដារដែលកំណត់ដោយ **ក.ជ.គ.** និងដែលត្រូវមានសង្គតិភាពជាមួយនឹងស្តង់ដារគណនេយ្យអន្តរជាតិពាក់ព័ន្ធជាធរមាន។

### មាត្រា១០ .- កាតព្វកិច្ចអនុវត្តស្តង់ដារគណនេយ្យកម្ពុជា

ស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មានកាតព្វកិច្ចអនុវត្តស្តង់ដារគណនេយ្យកម្ពុជា។

# ជំពូកទី៥

## ស្តង់ដារសវនកម្មកម្ពុជា

### មាត្រា១១ .- ស្តង់ដារសវនកម្មកម្ពុជា

ស្តង់ដារសវនកម្មកម្ពុជា គឺជាស្តង់ដារដែលកំណត់ដោយ **ក.ជ.គ.** និងដែលត្រូវមានសង្គតិភាពជាមួយនឹងស្តង់ដារសវនកម្មអន្តរជាតិពាក់ព័ន្ធជាធរមាន។

### មាត្រា១២ .- កាតព្វកិច្ចអនុវត្តស្តង់ដារសវនកម្ម

គណនេយ្យករកម្ពុជា មានកាតព្វកិច្ចអនុវត្តស្តង់ដារសវនកម្មកម្ពុជា។

# ជំពូកទី៦

## របាយការណ៍ហិរញ្ញវត្ថុ ការិយបរិច្ឆេទគណនេយ្យ និងកាតព្វកិច្ចរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ

### មាត្រា១៣ .- របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ រួមមានរបាយការណ៍នានាដែលកំណត់ដោយស្តង់ដារគណនេយ្យកម្ពុជា និងដែលត្រូវមានសង្គតិភាពជាមួយនឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិពាក់ព័ន្ធជាធរមាន។

### មាត្រា១៤ .- កាតព្វកិច្ចនិងថិរវេលានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រៅពីស្ថាប័នសាធារណៈ គ្រប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្នុងរយៈពេលបីខែយ៉ាងយូរបំផុត គិតពីថ្ងៃបិទការិយបរិច្ឆេទគណនេយ្យនីមួយៗ ដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់នេះ។ ប្រសិនបើសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញណាមិនអាចអនុវត្តបានតាមថិរវេលាកំណត់នេះទេ សហគ្រាសឬអង្គភាពនោះត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅ **ក.ជ.គ.** ដោយត្រូវសំអាងលើមូលហេតុសមស្របនិងច្បាស់លាស់។

**មាត្រា១៥ .- កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឲ្យធ្វើសវនកម្ម**

របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលជាប់កាតព្វកិច្ច ត្រូវរងការធ្វើសវនកម្ម។

បណ្ដាលក្ខខណ្ឌសម្រាប់ឲ្យសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់ របាយការណ៍ហិរញ្ញវត្ថុឲ្យធ្វើសវនកម្ម ត្រូវកំណត់ដោយ **ក.ជ.គ.**។

របាយការណ៍ហិរញ្ញវត្ថុដែលបានរងការធ្វើសវនកម្មរួចត្រូវដាក់ជូនទៅ **ក.ជ.គ.**។

**មាត្រា១៦ .- ការដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នសាធារណៈឲ្យធ្វើសវនកម្ម**

ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នសាធារណៈត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃ ច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

**មាត្រា១៧ .- របាយការណ៍ហិរញ្ញវត្ថុជាមូលដ្ឋានសម្រាប់ការប្រកាសពន្ធ**

របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ គឺជាមូលដ្ឋាន គ្រឹះសម្រាប់បម្រើឲ្យការប្រកាសពន្ធ ដោយរបាយការណ៍ទាំងនោះត្រូវបំពេញបន្ថែមដោយលក្ខខណ្ឌតម្រូវ នានាដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធដារ ជាធរមាន។

**មាត្រា១៨ .- ការិយបរិច្ឆេទគណនេយ្យ**

ការិយបរិច្ឆេទគណនេយ្យនីមួយៗមានរយៈពេល១២ (ដប់ពីរ)ខែ ដោយចាប់ផ្ដើមពីថ្ងៃទី១ ខែ មករា រហូតដល់ការបិទបញ្ជីគណនេយ្យនៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល។ ចំពោះសហគ្រាសឬអង្គភាព មិនស្វែងរកប្រាក់ចំណេញដែលបង្កើតឡើងថ្មី ការិយបរិច្ឆេទទី១ត្រូវចាប់ផ្ដើមនៅថ្ងៃបង្កើតសហគ្រាសឬ អង្គភាពនោះជាផ្លូវការ រហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំបន្ទាប់។

**ក.ជ.គ.** មានសិទ្ធិអំណាចកំណត់រយៈពេលនៃការិយបរិច្ឆេទគណនេយ្យដោយឡែកពីនេះ តាម សំណើជាលាយលក្ខណ៍អក្សររបស់សហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងនោះ សម្រាប់ សកម្មភាពដែលមានលក្ខណៈពិសេសណាមួយ ។

**មាត្រា១៩ .- ភាសា និងរូបិយវត្ថុដែលត្រូវប្រើក្នុងបញ្ជីគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុ**

សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញនីមួយៗត្រូវកាន់បញ្ជីគណនេយ្យនិងរៀបចំ របាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរនិងជាប្រាក់រៀល។ សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ទាំងឡាយណាដែលធ្វើប្រតិបត្តិការជាប្រចាំជាមួយបរទេស ត្រូវបានអនុញ្ញាតឲ្យកាន់បញ្ជីគណនេយ្យនិង រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាភាសាអង់គ្លេសនិង/ ឬជារូបិយប័ណ្ណផ្សេងពីប្រាក់រៀល ដើម្បី អមជាមួយ ស្របទៅតាមលក្ខខណ្ឌដែលកំណត់ដោយ **ក.ជ.គ.**។

**មាត្រា២០ .- កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ**

គ្រប់ស្ថាប័នសាធារណៈ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញមានកាតព្វកិច្ចកាន់បញ្ជី គណនេយ្យ។

ប្រតិបត្តិការគណនេយ្យនីមួយៗត្រូវសំអាងលើសក្ខីបត្រគណនេយ្យដែលអាចយកជាការបាន។

**មាត្រា២១ .- ភារកិច្ចរក្សាទុកឯកសារគណនេយ្យ**

គ្រប់សហគ្រាសនិងអង្គភាពមិនស្វែងប្រាក់ចំណេញ មានកាតព្វកិច្ចរក្សាទុកឯកសារគណនេយ្យរបស់ខ្លួនឱ្យបានគង់វង្សល្អ នៅក្នុងរយៈពេលយ៉ាងតិច១០(ដប់)ឆ្នាំ គិតពីកាលបរិច្ឆេទបង្កើតឯកសារទាំងនោះឡើង។

## ជំពូកទី៧

## របាយការណ៍សវនកម្ម

**មាត្រា២២ .- របាយការណ៍សវនកម្ម**

របាយការណ៍សវនកម្ម រួមមានរបាយការណ៍នានាដែលកំណត់ដោយស្តង់ដារសវនកម្មកម្ពុជា និងដែលត្រូវមានសង្គតិភាពជាមួយនឹងស្តង់ដារសវនកម្មអន្តរជាតិពាក់ព័ន្ធជាធរមាន។

**មាត្រា២៣ .- ភាសាដែលត្រូវប្រើក្នុងរបាយការណ៍សវនកម្ម**

ភាសាដែលត្រូវប្រើក្នុងរបាយការណ៍សវនកម្ម គឺភាសាខ្មែរ។

**មាត្រា២៤ .- ភស្តុតាងនៃសវនកម្ម**

ភស្តុតាងសវនកម្ម ត្រូវរក្សាទុក០៧(ប្រាំពីរ)ឆ្នាំយ៉ាងតិច គិតពីកាលបរិច្ឆេទចេញរបាយការណ៍សវនកម្ម។

## ជំពូកទី៨

## គណនេយ្យករកម្ពុជា និងភារកិច្ច

**មាត្រា២៥ .- គុណវុឌ្ឍិជាគណនេយ្យករកម្ពុជា**

រូបវន្តបុគ្គលឬនីតិបុគ្គល អាចកំណត់ខ្លួនឯងថាជា "គណនេយ្យករកម្ពុជា " បាន លុះត្រាតែរូបវន្តបុគ្គលឬនីតិបុគ្គលនោះជាសមាជិករបស់ **វ.គ.ជ.ក.** ។

ប្រភេទគណនេយ្យករកម្ពុជា ត្រូវកំណត់ដោយ **វ.គ.ជ.ក.** ។ are in conflict of Interest

ការប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬសវនកម្ម មានវិសមិតភាពជាមួយនឹងមុខងារសាធារណៈនិងមុខងារនយោបាយ ក្នុងអង្គការនីតិប្បញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងស្ថាប័នតុលាការ។

**មាត្រា២៦ .- ក្រមសីលធម៌នៃវិជ្ជាជីវៈនិងភារកិច្ចសម្រាប់គណនេយ្យករកម្ពុជា**

ក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជាត្រូវបង្កើតឡើងដោយ **វ.គ.ជ.ក.** និងត្រូវមានសង្គតិភាពជាមួយនឹងក្រមសីលធម៌នៃវិជ្ជាជីវៈអន្តរជាតិសម្រាប់គណនេយ្យករជំនាញ ជាធរមាន។

គ្រប់សមាជិករបស់ **វ.គ.ជ.ក.** មានកាតព្វកិច្ចអនុវត្តតាមក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជា ដែលកំណត់ខាងលើ។

# ជំពូកទី៩
## អាជ្ញាបណ្ណ

**មាត្រា២៧ .- ការតម្រូវឲ្យមានអាជ្ញាបណ្ណ**

រូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ អាចប្រកបវិជ្ជាជីវៈគណនេយ្យឬសវនកម្មបាន លុះត្រាតែជាសមាជិក **វ.គ.ជ.ក.** ដែលមានគុណវុឌ្ឍិប្រកបវិជ្ជាជីវៈនេះ និងត្រូវមានអាជ្ញាបណ្ណពី **ក.ជ.គ.** ជាមុន។

**មាត្រា២៨ .- ប្រភេទ នីតិវិធី និងបែបបទនៃការផ្ដល់អាជ្ញាបណ្ណ**

អាជ្ញាបណ្ណមាន២ (ពីរ) ប្រភេទគឺ÷

- អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ
- អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម។

លក្ខខណ្ឌ នីតិវិធី និងបែបបទនៃការផ្ដល់អាជ្ញាបណ្ណត្រូវកំណត់ដោយ **ក.ជ.គ.**។

# ជំពូកទី១០
## ទោសប្បញ្ញត្តិ

**មាត្រា២៩ .- ការមិនអនុវត្តស្តង់ដារគណនេយ្យកម្ពុជា**

នីតិបុគ្គលជាប់កាតព្វកិច្ច ដែលប្រព្រឹត្តល្មើសដោយចេតនានឹងមាត្រា៩ និង/ឬមាត្រា១០ នៃច្បាប់នេះ ត្រូវរងការផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន)រៀល។

រូបវន្តបុគ្គលដែលជាអ្នកទទួលខុសត្រូវនៃនីតិបុគ្គលខាងលើ ត្រូវរងការផ្ដន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៣(បី) ឆ្នាំ។

**មាត្រា៣០ .- ការមិនអនុវត្តស្តង់ដារសវនកម្មកម្ពុជា**

នីតិបុគ្គលជាសវនករ ដែលប្រព្រឹត្តល្មើសដោយចេតនានឹងមាត្រា១១ និង/ឬមាត្រា១២ នៃច្បាប់នេះ ត្រូវរងការផ្ដន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន)រៀល ដល់ ១០០.០០០.០០០ (មួយរយលាន)រៀល។

រូបវន្តបុគ្គលជាអ្នកទទួលខុសត្រូវនៃនីតិបុគ្គលជាសវនករ ត្រូវរងការផ្ដន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៣(បី) ឆ្នាំ។

**មាត្រា៣១ .- ការមិនដាក់របាយការណ៍ហិរញ្ញវត្ថុឲ្យធ្វើសវនកម្ម**

នីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងមាត្រា១៥ នៃច្បាប់នេះ ត្រូវរងការផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន)រៀល ដល់ ៤០.០០០.០០០ (សែសិបលាន)រៀល។

រូបវន្តបុគ្គលដែលជាអ្នកទទួលខុសត្រូវនៃនីតិបុគ្គលខាងលើ ត្រូវរងការផ្ដន្ទាទោសជាប់ពន្ធនាគារពី ០១(មួយ)ឆ្នាំ ដល់ ២(ពីរ) ឆ្នាំ។

**មាត្រា៣២ .- ការបំពានលើក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជា**

រូបវន្តបុគ្គលជាគណនេយ្យករកម្ពុជាណាដែលបំពានដោយចេតនាលើក្រមសីលធម៌នៃវិជ្ជាជីវៈសម្រាប់គណនេយ្យករកម្ពុជា ដូចមានចែងក្នុងមាត្រា២៦ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន)រៀល ដល់ ៤០.០០០.០០០ (សែសិបលាន)រៀល។

**មាត្រា៣៣ .- ការប្រកបវិជ្ជាជីវៈដោយគ្មានអាជ្ញាប័ណ្ណ**

គណនេយ្យករកម្ពុជាជានីតិបុគ្គលណាដែលប្រកបវិជ្ជាជីវៈគណនេយ្យ ឬសវនកម្ម ដោយគ្មានអាជ្ញាប័ណ្ណពី **គ.ជ.គ.** ជាមុន ឬប្រកបវិជ្ជាជីវៈមិនស្របតាមអាជ្ញាប័ណ្ណដែលបានផ្តល់ឱ្យ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន)រៀល ដល់ ៤០.០០០.០០០ (សែសិបលាន)រៀល ។

គណនេយ្យករកម្ពុជាជារូបវន្តបុគ្គលជាអ្នកទទួលខុសត្រូវនៃនីតិបុគ្គលខាងលើ ត្រូវរងការផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៣(បី) ឆ្នាំ។

**មាត្រា៣៤ .- ការមិនសហការជាមួយ គ.ជ.គ. និង ទ.គ.ជ.គ.**

រូបវន្តបុគ្គលឬនីតិបុគ្គលណាមិនសហការជាមួយ **គ.ជ.គ.** ដែលបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងចំណុចទី៤ មាត្រា៦ នៃច្បាប់នេះ ត្រូវរងការពិន័យអន្តរការណ៍តាមមាត្រា៣៥នៃច្បាប់នេះ។

គណនេយ្យករកម្ពុជាប្រកបវិជ្ជាជីវៈគណនេយ្យឬសវនកម្ម មិនសហការជាមួយ **គ.ជ.គ.** ឬ **ទ.គ.ជ.គ.** ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងមាត្រា៦ និងមាត្រា៨ នៃច្បាប់នេះ ត្រូវរងទណ្ឌកម្មបន្ថែមដូចបានកំណត់ក្នុងមាត្រា៣៥ នៃច្បាប់នេះ។

**មាត្រា៣៥ .- ទណ្ឌកម្មបន្ថែម**

ក្រៅពីទណ្ឌកម្មខាងព្រហ្មទណ្ឌតាមមាត្រាទាំងឡាយខាងលើ រូបវន្តបុគ្គលឬនីតិបុគ្គលត្រូវរងការពិន័យអន្តរការណ៍ និង/ឬទណ្ឌកម្មខាងវិន័យ និង/ឬទណ្ឌកម្មខាងរដ្ឋបាល ដែលត្រូវកំណត់ក្នុងអនុក្រឹត្យ។

# ជំពូកទី១១

## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .- វិធានការអន្តរកាល**

១-អនុក្រឹត្យ លេខ០៨ អនក្រ-បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ អនុក្រឹត្យ លេខ១៨ អនក្រ-បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងអនុក្រឹត្យ លេខ៨៣ អនក្រ-បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីក្រមសីលធម៌សម្រាប់គណនេយ្យករជំនាញនិងសវនករ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ត្រូវបន្តមានសុពលភាពរហូតដល់មានអនុក្រឹត្យនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធថ្មីមកជំនួស ក្នុងក្របខ័ណ្ឌនៃការអនុវត្តច្បាប់នេះ ។

២-អនុក្រឹត្យ លេខ៨២ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ត្រូវបន្តមានសុពលភាពរហូតដល់មានអនុក្រឹត្យនិងលិខិតបទដ្ឋាន គតិយុត្តពាក់ព័ន្ធថ្មីមកជំនួស ក្នុងក្របខ័ណ្ឌនៃការអនុវត្តច្បាប់នេះ ។

# ជំពូកទី១២

# អវសានប្បញ្ញត្តិ

**មាត្រា៣៧ .- បទប្បញ្ញត្តិដែលត្រូវនិរាករណ៍**

ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាសនិងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ក្នុងករណីមានទំនាស់រវាងច្បាប់នេះនិងច្បាប់ផ្សេងៗទៀត បទប្បញ្ញត្តិនៃច្បាប់នេះត្រូវមានអាទិភាព ។

**មាត្រា៣៨ .- ការចូលជាធរមាន**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ..........

**ព្រះហស្តលេខានិងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
សម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូន
សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា

**គាត ឈន់**